# សិទ្ធិមើលពត៌មាននិងការកែតម្រូវ

លោកអ្នកមានសិទ្ធិមើលពត៌មានផ្ទាល់ខ្លួនអំពីរូបលោកអ្នកដែល **WAYSS Ltd** រក្សាទុក។លោកអ្នកក៏មានសិទ្ធិកែតម្រូវពត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកដែលគេរក្សាទុកផងដែរ បើសិនជាព័ត៌មាននោះមិនត្រឹមត្រូវ។

ដើម្បីមើលសំណុំឯកសារ **WAYSS Ltd** របស់លោកអ្នក គឺលោកអ្នកគ្រាន់តែស្នើសុំឲ្យបុគ្គលិកថតចម្លងឯកសារនោះឲ្យលោកអ្នកទៅបានហើយ។ ពេលនោះគេនឹងស្នើសុំឲ្យលោកអ្នកចុះហត្ថលេខាលើឯកសារបំពេញពាក្យសុំមើលពត៌មានដែលនិយាយថា លោកអ្នកបានយកពត៌មាននេះទៅជាមួយលោកអ្នក។ **WAYSS Ltd** នឹងព្យាយាមបំពេញតាមសំណូមពររបស់លោកអ្នកទៅតាមពេលវេលាដែលសមស្រប។

បើមានការបដិសេធទៅនឹងសំណូមពរសុំមើលឯកសារពត៌មាននោះ លោកអ្នកនឹងទទួលដំណឹងជាលាយល័ក្ខណ៍អក្សរ។ ការសុំមើលសំណុំឯកសារពត៌មានទាំងឡាយ អាចផ្តល់ជូនតែចំពោះអតិថិជនផ្ទាល់ឬក៏តំណាងតាមផ្លូវច្បាប់ដែលមានការអនុញ្ញាតត្រឹមត្រូវពីអតិថិជនទាំងនោះប៉ុណ្ណោះ។

**WAYSS**
**LTD**

*Providing Housing*
*& Support Services*
*in the Community*

**WAYSS Limited**
ABN 38 080 191 108

ទូរស័ព្ទ៖ **(03) 9791 6111**
ទូរសារ៖ **(03) 9793 5078**
អ៊ីមែល៖ **info@wayssltd.org.au**

# តើត្រូវធ្វើអ្វីបើលោកអ្នកគិតថាមានការបំពានលើភាពសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក

*បើសិនជាលោកអ្នកមានអារម្មណ៍ថាមានការបំពានទៅលើភាពសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក លោកអ្នកអាចទាក់ទងស្ថាប័នណាមួយខាងក្រោមនេះដើម្បីសុំការណែនាំបន្ថែម៖*

## ស្នងការរក្សាភាពសម្ងាត់ផ្ទាល់ខ្លួនក្នុងរដ្ឋវិកតូរីយ៉ា

**Level 11, 10-16 Queen Street**
**Melbourne. 3000**

ទូរស័ព្ទ៖ **8619 8719**
**1300 666 444**

## ស្នងការសេវាសុខភាព

**30th floor, 570 Bourke Street**
**Melbourne. 3000**

ទូរស័ព្ទ៖ **8601 5200**
**1800 136 066**

ស្នងការទាំងពីរមានអំណាចក្នុងការធ្វើការស៊ើបអង្កេត ទាក់ទងទៅនឹងការអនុវត្តន៍ផ្នែកពត៌មានសម្ងាត់ផ្ទាល់ខ្លួន ហើយអាចចេញបញ្ជាឲ្យគោរពតាមដោយរួមទាំងការផាកពិន័យបើសិនជាមានការបំពានលើភាពសម្ងាត់ផ្ទាល់ខ្លួនណាមួយនោះ។ លោកអ្នកក៏អាចប្រើនីតិវិធីផ្ទៃក្នុងតាមរយៈការដាក់បណ្តឹង **(Internal Grievance Procedure)** ជាមួយនឹង **WAYSS Ltd** ដោយមានជំនួយពីបុគ្គលិកនៃស្ថាប័នមួយផ្សេងទៀត បើសិនជាលោកអ្នកចង់។ សម្រាប់ពត៌មានបន្ថែម លោកអ្នកអាចទាក់ទង WAYSS Ltd តាមរយៈទូរស័ព្ទលេខ៖ **9791 6111**។

DCN. 138/7

**WAYSS**
**LTD**

*Providing Housing*
*& Support Services*
*in the Community*

# ពត៌មានសម្ងាត់ផ្ទាល់ខ្លួន

ការិយាល័យដែលបានចុះឈ្មោះ៖
**294-300 Thomas Street**
**Dandenong Vic 3175**

ទូរស័ព្ទ៖ **(03) 9791 6111**
ទូរសារ៖ **(03) 9793 5078**
អ៊ីមែល៖ **info@wayssltd.org.au**
វ៉ិបសាយថ៍៖ **www.wayssltd.org.au**

**WAYSS** គឺជាស្ថាប័នដែលមានការចុះឈ្មោះត្រឹមត្រូវសម្រាប់ការផ្តល់ជំនួយផ្នែកទីលំនៅនិងជាសេវាដែលមានការទទួលស្គាល់ដើម្បីជួយជនដែលគ្មានទីលំនៅ។